NEWS
RELEASE

UNITED NATIONS
HUMAN RIGHTS
SPECIAL PROCEDURES
SPECIAL RAPPORTEURS, INDEPENDENT EXPERTS & WORKING GROUPS

# "ប្រទេសកម្ពុជាបានមកដល់ផ្លូវបំបែកហើយ"៖ អ្នកជំនាញ អ.ស.ប អំពាវនាវឲ្យរដ្ឋាភិបាលជ្រើសរើសដើរតាមមាគ៌ាសិទ្ធិមនុស្ស

រាជធានីភ្នំពេញ (ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៨) – អ្នកជំនាញ អ.ស.ប ស្ដីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា បានសម្ដែងកង្វល់យ៉ាងខ្លាំងអំពីការរឹតត្បិតលើប្រព័ន្ធផ្សព្វផ្សាយ សេរីភាពក្នុងការបញ្ចេញមតិ និងការចូលរួមក្នុងសកម្មភាពនយោបាយ នៅមុនពេលនៃការបោះឆ្នោតជាតិក្នុងខែកក្កដា ដោយអំពាវនាវឲ្យរដ្ឋាភិបាលជ្រើសរើសដើរតាមមាគ៌ាសិទ្ធិមនុស្ស។

"ប្រទេសកម្ពុជាមកដល់ផ្លូវបំបែកមួយដ៏សំខាន់ ហើយត្រូវតែចាប់យកសិទ្ធិមនុស្សដែលចាំបាច់មិនអាចខ្វះបានក្នុងការទ្រទ្រង់ដល់ការអភិវឌ្ឍ និងសន្តិភាពដែលរកបានដោយពិបាក" អ្នកស្រី រ៉ូណា ស្មីត បានមានប្រសាសន៍នៅចុងនៃដំណើរទស្សនកិច្ចលើកទីប្រាំ របស់អ្នកស្រីមកកាន់ប្រទេសកម្ពុជា។

"ការរឹតត្បិតសំឡេងប្រជាជនកម្ពុជា នៅទីបំផុតអាចគំរាមកំហែងដល់ស្ថិរភាពពិតប្រាកដដែលរដ្ឋាភិបាល និងប្រជាជនបានខិតខំកសាងឡើងដោយលំបាក។ សេរីភាពក្នុងការបង្កើតសមាគម ការបញ្ចេញមតិ និងការជួបប្រជុំដោយសន្តិវិធី គួរតែត្រូវបានការពារ និងបង្កើតឡើង មិនត្រូវធ្វើការរឹតត្បិតឡើយ នៅក្នុងលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ដែលត្រូវបានធានាការពារដោយរដ្ឋធម្មនុញ្ញកម្ពុជា"។

អ្នកស្រី ស្មីត បានលើកឡើងពីដំណើរវិវឌ្ឍន៍គួរឲ្យព្រួយបារម្ភនាពេលថ្មីៗនេះ រាប់ទាំងការបិទស្ថានីយវិទ្យុក្នុងស្រុកមួយចំនួន និងកាសែតក្នុងស្រុកមួយ ការរំលាយគណបក្សប្រឆាំងដ៏ធំមួយ និងការបែងចែកអាសនៈរបស់គណបក្សនេះ ការចាប់បដិបក្ខនយោបាយដាក់ពន្ធនាគារ និងសកម្មជនសិទ្ធិមនុស្ស ការប្រើច្បាប់ថ្មីដើម្បីកាត់បន្ថយសេរីភាព ការចូលរួមក្នុងសកម្មភាពនយោបាយ និងសកម្មភាពសង្គមស៊ីវិល។

"ចំពោះប្រជាជនកម្ពុជា ដែលបានបោះឆ្នោតថ្នាក់ជាតិក្នុងឆ្នាំ២០១៣ និងបោះឆ្នោតឃុំ/សង្កាត់ក្នុងឆ្នាំ២០១៧ អាសនៈតំណាងរបស់ពួកគេ បច្ចុប្បន្ននេះ ត្រូវបានកាន់កាប់ដោយអ្នកដែលពួកគេមិនបានបោះឆ្នោតឲ្យ ឬសូម្បីតែស្គាល់ក៏គេមិនស្គាល់ផង។ អ្នកស្រី ស្មីត បានមានប្រសាសន៍ថា បញ្ហានេះបាននាំឲ្យមានកង្វល់យ៉ាងខ្លាំងអំពីសិទ្ធិចូលរួមក្នុងសកម្មភាពនយោបាយ" ហើយអ្នកស្រីបានស្នើឲ្យអាជ្ញាធរ "បង្វែរជាបន្ទាន់នូវចំណាត់ការនានាពេលថ្មីៗនេះ" ហើយដកការហាមប្រាមអ្នកនយោបាយចំនួន ១១៨ រូប មិនឲ្យចូលរួមក្នុងសកម្មភាពនយោបាយ។

សិទ្ធិចូលរួមក្នុងសកម្មភាពនយោបាយ និងសេរីភាពក្នុងការបញ្ចេញមតិមានសារៈសំខាន់ជាពិសេសក្នុងដំណើរការបោះឆ្នោត ហើយអាជ្ញាធរមានទំនួលខុសត្រូវក្នុងការធានាថា បុគ្គល គណបក្សនយោបាយនានា និងប្រព័ន្ធផ្សព្វផ្សាយ អាចដំណើរការបានដោយមិនមានការគំរាមកំហែង ឬដាក់ទណ្ឌកម្មឡើយ"។

អ្នកស្រី ស្មីត ក៏បានសម្តែងកង្វល់យ៉ាងខ្លាំងចំពោះរបាយការណ៍អំពីការបាញ់ប្រហារ កាលពីថ្ងៃទី៨ ខែមីនា នៅខេត្តក្រចេះ ទាក់ទងនឹងទំនាស់ដីធ្លី។ "ខ្ញុំបាន និងកំពុងតាមដានស្ថានភាពនេះយ៉ាងយកចិត្តទុកដាក់ ដោយលើកពីកង្វល់របស់ខ្ញុំដោយផ្ទាល់ នៅពេលជួបប្រជុំជាមួយមន្ត្រីរដ្ឋាភិបាល ហើយបានអំពាវនាវឲ្យមានការស៊ើបអង្កេតជាបន្ទាន់ និងដោយឯករាជ្យ"។

អ្នកស្រីបានមានប្រសាសន៍ថា "ជាថ្មីម្តងទៀត ឧបទ្ទវហេតុដូចនេះ បង្ហាញថា សិទ្ធិពលរដ្ឋ សិទ្ធិវប្បធម៌ សិទ្ធិសេដ្ឋកិច្ច សិទ្ធិនយោបាយ និងសិទ្ធិសង្គមកិច្ច មានការផ្សារភ្ជាប់គ្នា និងមានសារៈសំខាន់ដូចគ្នា។ សិទ្ធិមនុស្សមិនមែនជាការត្រូវលះបង់នោះឡើយ។ មូលហេតុដើមនៃភាពតានតឹង ត្រូវតែដោះស្រាយ ហើយទំនាស់ត្រូវតែដោះស្រាយដោយសន្តិភាព និងដោយមានការពិគ្រោះយោបល់"។

អ្នកជំនាញសិទ្ធិមនុស្ស អ.ស.ប ក៏សូមស្វាគមន៍ផងដែរចំពោះការបង្កើនការបែងចែកថវិកាសម្រាប់វិស័យសង្គម ដើម្បីលើកកម្ពស់សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។

អ្នកស្រី ស្មីត បានមានប្រសាសន៍ថា "ខ្ញុំលើកទឹកចិត្តដល់រដ្ឋាភិបាលសូមបន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនក្នុងវិស័យសុខាភិបាល សន្តិសុខសង្គម ការអប់រំ និងសូមធ្វើការងារតាមរយៈក្រសួងនានា និងរដ្ឋាភិបាលគ្រប់លំដាប់ថ្នាក់ ដើម្បីធានាថាសេវាកម្មទាំងនេះអាចរកបាន មានលទ្ធភាពប្រើប្រាស់បាន មានលក្ខណៈសមរម្យ និងមានគុណភាពខ្ពស់ សម្រាប់ប្រជាពលរដ្ឋកម្ពុជាគ្រប់រូប។ មិនគួរទុកនរណាម្នាក់ចោលឡើយ ដូចដែលបានសន្យានៅក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងរបៀបវារៈឆ្នាំ២០៣០"។

## ចប់

សូមអានសេចក្តីថ្លែងការណ៍ចុងបេសកកម្មរបស់អ្នករាយកាណ៍ពិសេស ៖ [http://bit.ly/2pclrRe](http://bit.ly/2pclrRe)

*__សាស្ត្រាចារ្យ រ៉ូណា ស្មីត__ (ចក្រភពអង់គ្លេស) ត្រូវបានក្រុមប្រឹក្សាសិទ្ធិមនុស្ស អ.ស.ប តែងតាំងជាអ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ក្នុងខែមីនា ឆ្នាំ២០១៥ ។*

*អ្នករាយការណ៍ពិសេស ពួកគាត់គឺជាផ្នែកមួយនៃអ្វីដែលគេស្គាល់ថាជានីតិវិធីពិសេសរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស។ នីតិវិធីពិសេស (ស្ថាប័នដ៏ធំបំផុតមួយនៃអ្នកជំនាញឯករាជ្យនៅក្នុងប្រព័ន្ធសិទ្ធិមនុស្ស អ.ស.ប) គឺជាឈ្មោះទូទៅមួយនៃយន្តការឃ្លាំមើល និងស្វែងរកការពិតឯករាជ្យរបស់ក្រុមប្រឹក្សានេះ។ អ្នកកាន់អាណត្តិនីតិវិធីពិសេស គឺជាអ្នកជំនាញឯករាជ្យ ដែលក្រុមប្រឹក្សាសិទ្ធិមនុស្សបានតែងតាំងឡើង ដើម្បីធ្វើការងារពាក់ព័ន្ធនឹងស្ថានភាពសិទ្ធិមនុស្សរបស់ប្រទេសមួយជាក់លាក់ ឬបញ្ហាសិទ្ធិមនុស្សតាមវិស័យនីមួយៗ នៅគ្រប់តំបន់ទាំងអស់នៃពិភពលោក។ ពួកគាត់មិនមែនជាបុគ្គលិក អ.ស.ប ទេ ហើយធ្វើការឯករាជ្យពីរដ្ឋាភិបាល និង អ.ស.ប។ ពួកគាត់បំរើការក្នុងសមត្ថភាពបុគ្គលផ្ទាល់របស់ខ្លួន ហើយមិនទទួលប្រាក់បៀវត្សរ៍លើការងារនេះឡើយ។*

*ពិនិត្យមើលរបាយការណ៍របស់អ្នករាយការណ៍ពិសេសស្ដីពីប្រទេសកម្ពុជា។*

*សិទ្ធិមនុស្ស អ.ស.ប គេហទំព័រសម្រាប់ប្រទេស៖ កម្ពុជា*

*សម្រាប់ព័ត៌មានបន្ថែម និងការសាកសួរព័ត៌មានផ្សេងៗ សូមទាក់ទង៖*
*លោក ម៉ាស៍មូដ ហ្គារហ្គា* (Mahmoud Garga) *តាមរយៈទូរស័ព្ទលេខ៖ (+៨៥៥ (0)១២ ៧៩០ ១៧៨ ឬ អ៊ីម៉ែល* *mgarga@ohchr.org )*

*អ្នកស្រី អ៊ីស្ទ័រ ឡាំ* (Esther Lam) *តាមរយៈទូរស័ព្ទលេខ៖ (+៤១ ៧៩ ៤៤៤ ៣៩៤0 ឬ អ៊ីម៉ែល* *mgarga@ohchr.org )*

*សម្រាប់**ការសាកសួរព័ត៌មាន**ពាក់ព័ន្ធនឹងអ្នកជំនាញឯករាជ្យដទៃទៀតរបស់ អ.ស.ប សូមទាក់ទង៖*
*លោក ហ្សេរ៉ូមី ឡូរង់ស៍* (Jeremy Laurence) *សិទ្ធិមនុស្ស អ.ស.ប– អង្គភាពប្រព័ន្ធផ្សព្វផ្សាយ តាមរយៈទូរស័ព្ទលេខ៖ (+៤១ ២២ ៩១៧ ៩៣៨៣ ឬ អ៊ីម៉ែល* jlaurence@ohchr.org)

*ឆ្នាំ២០១៨ នេះ គឺជា**ខួបលើកទី៧0 នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស** ដែលអង្គការសហប្រជាជាតិបាន អនុម័តនៅថ្ងៃទី១0 ខែធ្នូ ឆ្នាំ១៩៤៨។ សេចក្តីប្រកាសជាសកលនេះជាប់លំដាប់ថ្នាក់ពិភពលោក ផ្នែកខាងអត្ថបទដែលត្រូវបានបកប្រែជា ៥00 ភាសា ដោយផ្អែកលើគោលការណ៍គ្រឹះដែលថា «មនុស្សគ្រប់រូបកើតមកមានសេរីភាព និង សមភាពខាងសេចក្តីថ្លៃថ្នូរនិងសិទ្ធិ»។ គោលការណ៍គ្រឹះនេះ ស្ថិតនៅជាមួយមនុស្សគ្រប់រូប ជារៀងរាល់ថ្ងៃ។ ដើម្បីគោរពខួបលើកទី៧0 នៃឯកសារដែលមានឥទ្ធិពលដ៏វិសេសវិសាលនេះ និងដើម្បីរក្សាគោលការណ៍នេះកុំឲ្យបាត់បង់ យើងសូមស្នើឲ្យមនុស្សគ្រប់រូបនៅលើពិភពលោក **ក្រោកឈរឡើងដើម្បីសិទ្ធិមនុស្ស៖*** *www.standup4humanrights.org.*